ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខ: ៥២៧ ព្រ.ក...... អអរ

# សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពី
## លទ្ធផលនៃដំណើរទស្សនកិច្ចផ្លូវការរបស់ ឯកឧត្តមបណ្ឌិត សនសៃ ស៊ីផាន់ដន នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅព្រះរាជាណាចក្រកម្ពុជា

**ឯកឧត្តមបណ្ឌិត សនសៃ ស៊ីផាន់ដន** (Sonexay SIPHANDONE) នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងលោកជំទាវ **វណ្ណដាឡា ស៊ីផាន់ដន** (Vandala SIPHANDONE) រួមទាំងគណៈប្រតិភូជាន់ខ្ពស់រដ្ឋាភិបាលឡាវ បានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការរយៈពេល២ថ្ងៃ ចាប់ពីថ្ងៃទី ៤-៥ ខែធ្នូ ឆ្នាំ២០២៤ នៅព្រះរាជាណាចក្រកម្ពុជា តបតាមការអញ្ជើញរបស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។

ក្នុងអំឡុងពេលបំពេញទស្សនកិច្ចផ្លូវការនេះ ប្រមុខរដ្ឋាភិបាលឡាវ បានអញ្ជើញចូលក្រាបថ្វាយបង្គំគាល់ **ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះបរមរាជវាំង។ ជំនួបសម្ដែងការគួរសមជាមួយ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា **សម្ដេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា និងជំនួបទ្វេភាគីជាមួយ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ជំនួបទ្វេភាគី

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់រាជរដ្ឋាភិបាល សម្ដែងនូវការស្វាគមន៍យ៉ាងកក់ក្ដៅបំផុតក្នុងពិធីបដិសណ្ឋារកិច្ចផ្លូវការប្រកបដោយកិត្តិយសជូន **ឯកឧត្តមបណ្ឌិត សនសៃ ស៊ីផាន់ដន នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ** និងលោកជំទាវ **វណ្ណដាឡា ស៊ីផាន់ដន** រួមទាំងគណៈប្រតិភូជាន់ខ្ពស់រដ្ឋាភិបាលឡាវ នៅវិមានសន្តិភាព។ **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** និង**ឯកឧត្តមនាយករដ្ឋមន្ត្រីឡាវ** បានសម្ដែងនូវការពេញចិត្តយ៉ាងខ្លាំងចំពោះវឌ្ឍនភាពនៃទំនាក់ទំនងជាប្រពៃណី ជាអ្នកជិតខាងល្អ



ទីស្ដីការគណៈរដ្ឋមន្ត្រី លេខ៤១ មហាវិថីសហពន្ធរុស្ស៊ី (១១០). រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Website : rgsu.gov.kh / Facebook page : Royal Government Spokesperson Unit / Telegram : https : // t. me / Cambodia Government Spokesperson

និងកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងយូរអង្វែង រវាងប្រទេសទាំងពីរ។ ប្រមុខរដ្ឋាភិបាលទាំងពីរបានលើកទឹកចិត្តឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធ បន្តជំរុញការពង្រឹងកិច្ចសហប្រតិបត្តិការឱ្យកាន់តែរឹងមាំនិងជិតស្និទ្ធថែមទៀត និងគាំទ្រឱ្យមានការផ្លាស់ប្តូរដំណើរទស្សនកិច្ចរវាងគណៈប្រតិភូនៅគ្រប់កម្រិត រួមទាំងយុវជន និងយុវជន។

ប្រមុខរដ្ឋាភិបាលទាំងពីរបានឯកភាពបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗ រួមមានវិស័យនយោបាយនិងការទូត សេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគនិងហិរញ្ញវត្ថុ ការពារជាតិនិងសន្តិសុខ ថាមពល ការដឹកជញ្ជូននិងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ អប់រំ ទេសចរណ៍ វប្បធម៌និងសិល្បៈ ព្រមទាំងកិច្ចសហការក្នុងក្របខ័ណ្ឌតំបន់ និងអន្តរជាតិ។

ជាមួយគ្នានេះ ប្រមុខរដ្ឋាភិបាលកម្ពុជា-ឡាវ បានអញ្ជើញធ្វើជាអធិបតីក្នុងពិធីចុះកិច្ចព្រមព្រៀង និងអនុស្សរណៈនៃការយោគយល់គ្នា ចំនួន ៣ រួមមាន៖

១. កិច្ចព្រមព្រៀងស្តីពី ការលុបបំបាត់ការយកពន្ធត្រួតគ្នា ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ។

២. អនុស្សរណៈនៃការយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម។

៣. អនុស្សរណៈនៃការយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការលើវិស័យវប្បធម៌ និងសិល្បៈ សម្រាប់ឆ្នាំ២០២៥-២០២៧។

ក្នុងអំឡុងពេលទស្សនកិច្ចផ្លូវការនេះ ភាគីទាំងពីរបានចេញសេចក្តីថ្លែងការណ៍រួមចំនួន ២៣ចំណុច មានដូចជា សិក្សាលទ្ធភាពការបើកច្រកព្រំដែនថ្មី (ខេត្តរតនគិរី-ខេត្តអាត់តាពឺ) ពន្លឿនការជ្រើសរើសទីតាំងសម្រាប់សាងសង់ស្ពានឆ្លងកាត់ទន្លេរពៅ (ខេត្តព្រះវិហារ) - ទន្លេសេឡាំប៉ាវ (ខេត្តចំប៉ាសាក់) ការរិះរកលទ្ធភាពនៃការបង្កើនជើងហោះហើរត្រង់ លើកទឹកចិត្តឱ្យធ្វើទេសចរណ៍តាមរយៈការបើកបរដោយខ្លួនឯងរវាងប្រទេសទាំងពីរ ប្តេជ្ញាពន្លឿនការដោះស្រាយតំបន់ព្រំដែនដែលនៅសេសសល់ឱ្យបានឆាប់ និងកិច្ចសហប្រតិបត្តិការវិស័យថាមពល ការពារជាតិនិងសន្តិសុខ ជាដើម។

ក្នុងឱកាសដ៏វិសេសវិសាលនេះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានរៀបចំពិធីលៀងសាយភោជន៍ផ្លូវការទទួលស្វាគមន៍ប្រកបដោយភាពកក់ក្តៅ និងស្និទ្ធស្នាលជាទីបំផុតជូន **ឯកឧត្តមនាយករដ្ឋមន្ត្រីឡាវ** និង**លោកជំទាវ** រួមទាំងគណៈប្រតិភូជាន់ខ្ពស់រដ្ឋាភិបាលឡាវ នៅវិមានសន្តិភាព។

**ជំនួបសម្តែងការគួរសម**

នៅវិមានរដ្ឋសភា **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា** និង**ឯកឧត្តមនាយករដ្ឋមន្ត្រីឡាវ** បានប្តេជ្ញាចិត្តរួមគ្នាជំរុញនិងលើកកម្ពស់ទំនាក់ទំនងដ៏ល្អនៃប្រទេសទាំងពីរឱ្យកាន់តែរឹងមាំ និងអនុវត្តបានជាផ្លែផ្កានូវរាល់កិច្ចព្រមព្រៀង និងអនុស្សរណៈដែលប្រទេសទាំងពីរបានចុះហត្ថលេខាទាំងខាងស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ដើម្បីនាំមកនូវផលប្រយោជន៍ជូនប្រទេសទាំងសងខាង។ កម្ពុជានិងឡាវចាំបាច់ត្រូវបន្តរក្សាការប្រាស្រ័យទាក់ទងគ្នាជាយុទ្ធសាស្ត្រឱ្យបានកាន់តែល្អប្រសើរ និងស្អិតល្មួតនៅគ្រប់កម្រិត

និងគ្រប់វិស័យ ក្នុងនោះ រវាងបក្ស រដ្ឋាភិបាល រដ្ឋសភា វិស័យឯកជន និងសង្គមស៊ីវិល ដែលជាចាំបាច់ និងកាន់តែសំខាន់ឡើងក្នុងពេលបច្ចុប្បន្ន ដែលពិភពលោកកំពុងស្ថិតក្នុងភាពស្មុគស្មាញ ការប្រឈមកាន់តែខ្លាំងលើបញ្ហាភូមិសាស្ត្រនយោបាយ។ **សម្តេចប្រធានរដ្ឋសភា** និង**ប្រមុខរដ្ឋាភិបាលឡាវ** បានឯកភាពបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗ រួមមាន ការទូតសភា សេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ការពារជាតិ និងសន្តិសុខថាមពល ការដឹកជញ្ជូននិងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរវាងប្រទេសទាំងពីរ ក៏ដូចជាការតភ្ជាប់ប្រទេសទាំងពីរទៅកាន់បណ្ដាប្រទេសនានាក្នុងតំបន់ផងដែរ។

នៅវិមាន៧មករា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា** បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅជូនចំពោះ **ឯកឧត្តមនាយករដ្ឋមន្ត្រីឡាវ** និងគណៈប្រតិភូជាន់ខ្ពស់ដែលបានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា នាពេលនេះ។ **សម្តេចតេជោ** បានបន្ថែមថា **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** គ្រោងនឹងយាងបំពេញព្រះរាជទស្សនកិច្ចនៅប្រទេសឡាវ នាខែមករា ឆ្នាំ២០២៥ ខាងមុខនេះ។ **សម្តេចតេជោ** រីករាយនឹងការផ្លាស់ប្តូរទស្សនកិច្ចប្រកបដោយការចាប់ចិត្តរវាងប្រទេសទាំងពីរ។

**ឯកឧត្តមនាយករដ្ឋមន្ត្រីឡាវ** ពេញចិត្តជាខ្លាំងចំពោះសមិទ្ធផលនៃកិច្ចសហប្រតិបត្តិការតាមព្រំដែន ដែលភាគីទាំងពីរបានស្តាប់ទស្សនៈគ្នាទៅវិញទៅមក យោគយល់គ្នាអស់ពីចិត្តអស់ពីថ្លើម និងត្រង់ទៅត្រង់មក។ **ឯកឧត្តមនាយករដ្ឋមន្ត្រីឡាវ** បានស្នើឱ្យបរិយាកាសកិច្ចសហប្រតិបត្តិការមិត្តភាពដ៏ល្អនេះ បន្តទៅមុខដើម្បីឈានទៅដោះស្រាយកិច្ចការព្រំដែនរួមគ្នាប្រកបដោយការអភិវឌ្ឍ ពិសេសបន្តពូនថ្ម និងជំរុញកិច្ចសហប្រតិបត្តិការរវាងនាយករដ្ឋមន្ត្រី គណបក្ស និងប្រជាជន នៃប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរឡើង។

**សម្តេចតេជោ** បានជម្រាបជូន **ឯកឧត្តមនាយករដ្ឋមន្ត្រីឡាវ** ថា ដើម្បីរក្សាបាននូវសុខសន្តិភាពជូនប្រជាជនកម្ពុជាសម្រេចដកខ្លួនចេញពីកិច្ចសហប្រតិបត្តិការតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា ឡាវ វៀតណាម (CLV-DTA) ក៏ប៉ុន្តែការដកខ្លួនរបស់កម្ពុជានេះ មិនមែនដកកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងបីនោះទេ។ **សម្តេចតេជោ** បានបន្តទៀតថា ប្រទេសទាំងបីនឹងបន្តកិច្ចសហប្រតិបត្តិការតាមយន្តការដែលមានស្រាប់ជាទូទៅ និងកម្រិតប្រទេសតែម្តង និងបន្តពង្រីកបន្ថែមកិច្ចសហប្រតិបត្តិការនេះ ជាពិសេសតាមរយៈជំនួបជាទៀងទាត់នៃថ្នាក់ដឹកនាំគណបក្សកាន់អំណាច នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងកម្មវិធីអភិវឌ្ឍន៍យុវជននៃប្រទេសទាំងបី។ **ឯកឧត្តមនាយករដ្ឋមន្ត្រីឡាវ** បានសង្កត់ធ្ងន់ផងដែរថា ការដកខ្លួនរបស់កម្ពុជាចេញពី CLV-DTA ក្នុងនាមរដ្ឋាភិបាលឡាវ និងខ្លួនឯកឧត្តមផ្ទាល់ សូមសម្តែងនូវការយល់ចិត្តយល់ថ្លើមនៃការលំបាករបស់កម្ពុជា និងបានបញ្ជាក់ថា ឯកឧត្តម នឹងសហការយ៉ាងជិតស្និទ្ធជាមួយ **សម្តេចធិបតីនាយករដ្ឋមន្ត្រី**។

ក្នុងឱកាសនៃដំណើរទស្សនកិច្ចផ្លូវការនេះ **ឯកឧត្តមនាយករដ្ឋមន្ត្រីឡាវ** និងគណៈប្រតិភូជាន់ខ្ពស់ បានអញ្ជើញដាក់កម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធ នៅវិមានឯករាជ្យ និងនៅមណ្ឌបព្រះបរមរូប **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ "ព្រះបរមរតនកោដ្ឋ" អតីតព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** រួមទាំងអញ្ជើញទស្សនកិច្ចនៅតំបន់សេដ្ឋកិច្ចពិសេស រ៉ូយ៉ាល់ គ្រុប ភ្នំពេញ។

ដោយឡែក **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត ស្ត្រីទី១នៃកម្ពុជា** បានអញ្ជើញជូន **លោកជំទាវ ខណ្ណ្ណដាឡា ស៊ីផាន់ដន** ឧត្តមភរិយារបស់ **ឯកឧត្តមនាយករដ្ឋមន្ត្រីឡាវ** ទស្សនកិច្ចនៅព្រះបរមរាជវាំង និងសារមន្ទីរជាតិ នៃព្រះរាជាណាចក្រកម្ពុជា។

គួរកត់សម្គាល់ថា ក្រៅពីការអញ្ជើញទៅបំពេញទស្សនកិច្ច ឬចូលរួមកិច្ចប្រជុំនានានៅក្រៅប្រទេស ពីសំណាក់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល និងស្ថាប័នកំពូលៗរបស់ជាតិផ្សេងទៀត ទាំងក្នុងក្របខ័ណ្ឌតំបន់និងអន្តរជាតិ មេដឹកនាំបរទេសក៏បានអញ្ជើញមកបំពេញទស្សនកិច្ច និងចូលរួមកិច្ចប្រជុំនានានៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាជាបន្តបន្ទាប់ឥតដាច់។ ដំណើរទស្សនកិច្ចផ្លូវការរបស់ **ឯកឧត្តមនាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ** នាពេលនេះ គឺជាឧទាហរណ៍ជាក់ស្តែងមួយទៀត សបញ្ជាក់ឱ្យឃើញថា រាជរដ្ឋាភិបាលកម្ពុជាបានទទួលជោគជ័យកាន់តែខ្លាំងឡើងជាលំដាប់នៅក្នុងនយោបាយការទូតរបស់ខ្លួន ដោយកសាងបានទំនាក់ទំនងល្អ និងកាន់តែស៊ីជម្រៅជាមួយបណ្តាប្រទេសជាមិត្តនៅគ្រប់ជ្រុងជ្រោយនៃពិភពលោក។ ដំណើរទស្សនកិច្ចរបស់ប្រមុខរដ្ឋាភិបាលឡាវ ក៏បានពង្រឹងបន្ថែមទៀតនូវចំណងមិត្តភាពជាប្រពៃណីដ៏ល្អដែលមានស្រាប់ និងពង្រីកកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ដើម្បីជាឧត្តមប្រយោជន៍សម្រាប់ប្រទេសនិងប្រជាជនទាំងពីរ។

ព្រឹត្តិការណ៍ទាំងនេះក៏បានសបញ្ជាក់ឱ្យឃើញថា កម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលស្វាគមន៍យ៉ាងកក់ក្តៅនិងប្រកបដោយទំនុកចិត្តខ្ពស់ជូនគ្រប់បណ្តាថ្នាក់ដឹកនាំប្រទេសនៅលើពិភពលោក ក្នុងនាមជារដ្ឋអធិបតេយ្យមួយដែលកាន់តែមានកិត្យានុភាពនៅលើឆាកតំបន់ និងអន្តរជាតិ។ នេះគឺជាផ្លែផ្កានៃសុខសន្តិភាព ស្ថិរភាពនយោបាយដែលជាគ្រឹះនៃការអភិវឌ្ឍលើគ្រប់វិស័យ ហើយភ្ញៀវបរទេសតែងកោតសរសើរមិនដាច់ពីមាត់។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៤